**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៤

លេខ : ០៥/០៤...កបធ.ស.ជ.ណ

**ជំរាបជូន**

**ឯកឧត្តម លោកជំទាវ ជាតំណាងរាស្ត្រចំនួន ១៨ រូប**

**កម្មវត្ថុ :** សុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយនូវមាត្រាមួយចំនួននៃរដ្ឋធម្មនុញ្ញ ។

**យោង :** លិខិត ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០៤ របស់ឯកឧត្តម លោកជំទាវ ។

ក្រុមប្រឹក្សាធម្មនុញ្ញ បានទទួលពាក្យ របស់ ឯកឧត្តម លោកជំទាវ ដូចមានចែងក្នុងកម្មវត្ថុ និង យោងខាងលើនេះហើយ ប៉ុន្តែបានកត់សំគាល់ឃើញថា មិនមែនជាពាក្យសុំបកស្រាយសុទ្ធសាធទេ គឺមានការចោទប្រកាន់មកលើក្រុមប្រឹក្សាធម្មនុញ្ញថែមទៀតផង ដោយមានសរសេរថា " *យើងខ្ញុំសូមរៀបរយនូវសំណួរនេះឡើងវិញ ដោយសង្ឃឹមថាលើកនេះ ក្រុមប្រឹក្សាធម្មនុញ្ញនឹងមិនយកមូលហេតុណាទៀត ដើម្បីមិនធ្វើការបកស្រាយមាត្រានៃរដ្ឋធម្មនុញ្ញ...*" ។

ការចោទប្រកាន់បែបនេះ ជាការប្រមាថដល់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលជាស្ថាប័នច្បាប់កំពូលមួយ ។ ក្រុមប្រឹក្សាធម្មនុញ្ញ មិនអាចទទួលយកការចោទប្រកាន់នេះបានទេ ពីព្រោះក្រុមប្រឹក្សាធម្មនុញ្ញមិនដែល បានយកមូល-ហេតុមិនត្រឹមត្រូវណាមួយ មកបដិសេធពាក្យសុំបកស្រាយរដ្ឋធម្មនុញ្ញរបស់ឯកឧត្តម លោកជំទាវ ម្តងណាឡើយ ។ ការខុសទម្រង់ច្បាប់ គឺជាការខុសច្បាប់ ដែលធ្វើឱ្យរាំងស្ទះដល់ការទទួលពិនិត្យនូវបញ្ហាដែលឯកឧត្តម លោកជំទាវ បានលើកឡើងនោះ ។ ក្រុមប្រឹក្សាធម្មនុញ្ញមិនអាច និងមិនដែលធ្វើអ្វីឱ្យហួសពីច្បាប់កំណត់ឱ្យធ្វើបានឡើយ ។

ដោយហេតុថា ពាក្យសុំបកស្រាយរបស់ឯកឧត្តម លោកជំទាវ មិនមែនជាពាក្យសុំបកស្រាយរដ្ឋធម្មនុញ្ញសុទ្ធសាធទេនោះ ក្រុមប្រឹក្សាធម្មនុញ្ញ សូមបង្វិលពាក្យរបស់ឯកឧត្តម លោកជំទាវនេះ ត្រឡប់ជូនទៅឯកឧត្តម លោកជំទាវវិញ ។

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**